**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តឧត្តរមានជ័យ**

លេខ: ៣១៨/១៦ សជណ/ឧជ

*ឧត្តរមានជ័យថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៦*

# សេចក្តីជូនដំណឹង

## ស្តីពី

## ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៧

**សាលាខេត្តឧត្តរមានជ័យ** នឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ ២០១៧ សម្រាប់ដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៦ ។ អ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីអ្នកទទួលការមានសិទ្ធិដាក់សំណើដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ នៅគ្រប់គម្រោងមូលនិធិឃុំ សង្កាត់ ទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

អ្នកទទួលការត្រូវបានបែងចែកជា *០៣* ប្រភេទ ៖

*ប្រភេទទី ១*: អ្នកទទួលការសំណង់ទូទៅ ( ការងារសំណង់អគារ និងការងារបេតុង...។ល។)

*ប្រភេទទី ២*: អ្នកទទួលការការងារដី (ប្រឡាយ ទំនប់ ផ្លូវជីស ផ្លូវក្រាលគ្រួសក្រហម.....។ល។)

*ប្រភេទទី ៣*: អ្នកទទួលការឯកទេស (អ្នកទទួលការដែលមានឧបករណ៍ និងជំនាញពិសេស សម្រាប់ ការងារពិសេសដូចជា អណ្តូងស្នប់...។ល។)

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស សម្ភារៈ និងបរិក្ខារគ្រប់គ្រាន់ដូចមានបរិយាយនៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើ និងត្រូវមានបទពិសោធន៍អនុវត្តគម្រោងទាក់ទងនឹងប្រភេទនីមួយៗ ដែលបានស្នើសុំយ៉ាងតិចចំនួន០២ ក្នុងអំឡុងពេល០៥ ឆ្នាំចុងក្រោយ ។ អនុគណៈកម្មការបុរេលក្ខណសម្បត្តិ និងចុះពិនិត្យដល់ទីតាំងក្រុមហ៊ុនរបស់អ្នកទទួលការ និងវាយតម្លៃសមត្ថភាពបច្ចេកទេស ដោយផ្អែកលើលក្ខណវិនិច្ឆ័យដូចបានបរិយាយក្នុងពាក្យស្នើសុំចុះបញ្ជីព្រមទាំងពិនិត្យគុណភាពការងារ ភាពស្មោះត្រង់ការអនុវត្តការងារទាន់ពេលវេលា និងកិច្ចសហប្រតិបត្តិការរបស់អ្នកទទួលការជាមួយម្ចាស់គម្រោងដោយផ្អែកលើកំណត់ត្រាកន្លងមក ។ លទ្ធផលនៃការវាយតម្លៃនេះ អនុគណៈកម្មការបុរេលក្ខណសម្បត្តិនឹងដាក់ជូន **អភិបាលខេត្ត** ដើម្បីពិនិត្យនិងសម្រេច ។

អាស្រ័យហេតុនេះ បើអ្នកទទួលការណាមានបំណងចុះឈ្មោះក្នុងបញ្ជីអ្នកទទួលការ សូមប្រញាប់មកដាក់ពាក្យនៅ **ទីចាត់ការផែនការ និងវិនិយោគសាលាខេត្ត** ចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ថ្ងៃទី *២០* ខែ *តុលា* ឆ្នាំ *២០១៦* វេលាម៉ោង *០៥.០០* ល្ងាច ។ ចំពោះអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឆ្នាំកន្លងមក ក៏ត្រូវដាក់ពាក្យជាថ្មីឡើងវិញដែរ ។ អ្នកទទួលការអាចមកយកពាក្យសុំចុះឈ្មោះនៅទីចាត់ការផែនការ និងវិនិយោគសាលាខេត្ត ដោយឥតគិតថ្លៃរៀងរាល់ម៉ោងធ្វើការ ឬអាចទាញយកពីគេហទំព័ររបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ។

អាស្រ័យហេតុនេះ សូមសាធារណជន និងអ្នកទទួលការទាំងអស់មេត្តាជ្រាបជាព័ត៌មាន ។

**អភិបាលខេត្ត**

**ស ថាវី**

ចម្លងជូន

- *លេខាធិការដ្ឋាន គ.ជ.អ.ប*
  *(ដើម្បីគោរពជូនជ្រាប)*
- *ឯកសារ-កាលប្បវត្តិ*